multicultural health communication

NSW GOVERNMENT | Health

Khmer
[DOH-7180]

# ជំងឺឆ្កែឆ្កួត និង ជំងឺបង្កដោយលីស្សាវីរុស (Bat Lyssavirus) ដែលឃាយីសត្វប្រជៀវ
## Rabies and Bat Lyssavirus Infection

### តើ Lyssavirus ជាអ្វី?
Lyssavirus គឺជាប្រភេទវីរុសមួយក្រុមដែលក្នុងនោះមានមេរោគជំងឺឆ្កែឆ្កួត និងលីស្សាវីរុសដែលឃាយីសត្វប្រជៀវ (bat lyssavirus) ។ ជំងឺឆ្កែឆ្កួត គឺជាជម្ងឺម្យ៉ាងរបស់ពពួកថនិកសត្វ (សត្វចិញ្ចឹមកូនដោយទឹកដោះ) ដែលខាំនិងខ្វាំ។ នៅក្នុងខណៈពេលដែលជម្ងឺនេះកើតមាននៅទីកន្លែងជាច្រើនលើពិភពលោកនេះ ជម្ងឺនេះមិនកើតមានក្នុងប្រទេសអូស្ត្រាលីនេះទេ។ ការឆ្លងមេរោគជំងឺឆ្កែឆ្កួត អាចធ្វើឲ្យថនិកសត្វដែលឆ្លងមេរោគនេះទៅជាឈឺនិងងាប់បាន ហើយចំពោះមនុស្សវិញ កាលណាឆ្លងរោគនេះហើយ ច្រើនតែស្លាប់។

Bat lyssavirus ជាវីរុសមួយប្រភេទដែលជាប់សន្តានទៅនឹងមេរោគឆ្កែឆ្កួត ប៉ុន្តែមានលក្ខណៈខុសពីមេរោគនេះ។ នៅប្រទេសអូស្ត្រាលី មេរោគនេះមាននៅក្នុងខ្លួនសត្វប្រជៀវ។ មេរោគនេះកំរឆ្លងមកមនុស្សលោកណាស់ ។ ការឆ្លងមកមនុស្សនៃមេរោគ bat lyssavirus មានតែ ២ ករណីប៉ុណ្ណោះ ដែលត្រូវគេកត់ត្រាទុកនៅប្រទេសអូស្ត្រាលី ហើយអ្នកទាំងពីររស់នៅក្នុងរដ្ឋ Queensland នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០ ។ ពួកគេបានស្លាប់ទាំង២នាក់។

### តើជំងឺនេះមានរោគសញ្ញាអ្វីខ្លះ?
គេគិតថា ជំងឺឆ្កែឆ្កួត និង bat lyssavirus បង្កឲ្យមានរោគសញ្ញាប្រហាក់ប្រហែលគ្នា។ រោគសញ្ញាទាំងនេះរួមមានឈឺក្បាល, គ្រុនក្តៅ, អស់កំលាំងល្ហិតល្ហៃ, បំលាស់ប្តូរផ្នែកសរសៃប្រសាទនៅជុំវិញកន្លែងខាំឬខ្វាំនោះ, ភាពរំជើបរំជួលអារម្មណ៍, មិនចូលចិត្តខ្យល់អាកាសឬទឹក, ខ្សោយកំលាំង, រវើរវាយ, ប្រកាច់ និង សន្លប់។ ការស្លាប់ច្រើនកើតមានប៉ុន្មានថ្ងៃក្រោយពីការចាប់ផ្តើមលេចចេញរោគសញ្ញា។

### តើជំងឺទាំងនេះឆ្លងយ៉ាងដូចម្តេច?
ការចំលងមេរោគជំងឺឆ្កែឆ្កួត និង bat lyssavirus ពីថនិកសត្វដែលមានរោគ ទៅមនុស្ស ឬទៅថនិកសត្វដទៃទៀតកើតឡើងតាមរយៈការខាំ ឬ ការខ្វាំ។ ការខាំឬខ្វាំ អាចចាក់បញ្ចូលមេរោគដែលមាននៅក្នុងទឹកមាត់របស់សត្វទៅក្នុងរាងកាយមនុស្សដែលសត្វនោះខាំ ឬ ខ្វាំ។

នៅឯបរទេស ថនិកសត្វដែលមានផ្ទុកមេរោគនៃជំងឺឆ្កែឆ្កួត រួមមានប្រជៀវ, ឆ្កែ, ឆ្មា, raccoons, skunks, ស្វានិងថនិកសត្វដទៃទៀត ដែលអាចខាំនិងខ្វាំ។ ថនិកសត្វអូស្ត្រាលីមិនមានផ្ទុកមេរោគជំងឺឆ្កែឆ្កួតទេ។ នៅប្រទេសអូស្ត្រាលីមានតែសត្វប្រជៀវទេ ទាំងពពួកប្រជៀវហើរធំៗ (ឬប្រជៀវស៊ីផ្លែឈើ) និងពពួកប្រជៀវស៊ីសត្វល្អិត (មានមាឌតូចជាង) ប៉ុណ្ណោះដែលគេបានរកឃើញថាមានផ្ទុកមេរោគ bat lyssavirus ។

**តើនរណាប្រឈមមុខនឹងគ្រោះថ្នាក់ខ្លាំងជាងគេ?**
ចំពោះមេរោគជំងឺឆ្កែឆ្កួត បុគ្គលមកពីបរទេសដែលមានការប៉ះពាល់ជាមួយថនិកសត្វព្រៃ ដែលចេះខាំ និងខ្វាំ និង ពពួកថនិកសត្វស្រុកដែលមិនទាន់បានទទួលវ៉ាក់សាំងបង្ការមេរោគជំងឺឆ្កែឆ្កួតនៅឡើយ សុទ្ធសឹងជាបុគ្គល ប្រឈមនឹងការឆ្លងមេរោគនេះ។ មេរោគជំងឺឆ្កែឆ្កួតបានឆ្លងទៅប្រជាជនជាច្រើននៅឯបរទេស ហើយក៏បានឆ្លង ទៅជនជាតិអូស្ត្រាលីខ្លះដែលធ្វើដំណើរឬទៅរស់នៅបរទេសដែរ។

តំបន់មិនមានមេរោគជំងឺឆ្កែឆ្កួត ក្នុងឆ្នាំ២០០០ រួមមានប្រទេសអូស្ត្រាលី នូវ៉ែលហ្សេឡង់ ប៉ាពួនូវ៉ែលហ្គីនី ជប៉ុន ហាវៃ តៃវ៉ាន់ អូស៊ីអាណេ (Oceania) ផ្នែកខ្លះនៃទ្វីបអឺរ៉ុប ផ្នែកខ្លះនៃប្រជុំកោះការ៉ាអ៊ីប (West Indies) និងកោះ នានានៅមហាសមុទ្រអាត្លង់ទិក ។

នៅប្រទេសអូស្ត្រាលី មនុស្សទាំងឡាយដែលប៉ះពាល់ប្រជៀវប្រឈមមុខនឹងការឆ្លងមេរោគ bat lyssavirus។

**តើគេធ្វើរោគវិនិច្ឆ័យនិងព្យាបាលជំងឺនេះយ៉ាងដូចម្តេច?**
ការធ្វើរោគវិនិច្ឆ័យអាចមានការលំបាកហើយការបញ្ជាក់រោគវិនិច្ឆ័យនេះ តម្រូវឲ្យមានការធ្វើតេស្តនៅក្នុង មន្ទីរពិសោធន៍ ដើម្បីរកវត្តមាននៃមេរោគនេះ នៅក្នុងស្បែក, ឈាម, ទឹកខួរឆ្អឹងខ្នង និងជាលិកាសរសៃ ប្រសាទឬជាលិកាដទៃទៀត។ នៅពេលជម្ងឺនេះចាប់កើតឃាយើហើយនោះ គេពុំមានការព្យាបាលជម្ងឺនេះទេ។

**តើគេអាចបង្ការជម្ងឺនេះយ៉ាងដូចម្តេច?**
ប្រសិនបើវាមិនមែនជាការងារអ្នកទេ ហើយអ្នកមិនបានទទួលការបណ្តុះបណ្តាល និង ប្រើឧបករណ៍ការពារឲ្យ បានសមស្របទេនោះ ចូរកុំប៉ុនប៉ងប៉ះឬស្ទាបថនិកសត្វព្រៃឲ្យសោះ។ ជំងឺបង្កដោយ Bat lyssavirus និងជំងឺ ឆ្កែឆ្កួតគ្រាន់តែជាជំងឺ ២ ប៉ុណ្ណោះក្នុងចំណោមជំងឺជាច្រើនដែលសត្វអាចចំលងមកមនុស្សបាន។

ការលាងសំអាតរបួសបង្កដោយសត្វឲ្យបានស្អាតល្អ និងការលាបទឹងថ្នាំសូលុយស្យុងប្រឆាំងមេរោគ ដូចជា povidone-iodine ជាដើមនឹងជួយបង្ការពីការឆ្លងរោគ។

វ៉ាក់សាំងប្រឆាំងមេរោគជំងឺឆ្កែឆ្កួត អាចជួយបង្ការការចម្លងទាំងមេរោគជំងឺឆ្កែឆ្កួត ផងនិង bat lyssavirus ផង។ បុគ្គលទាំងឡាយដែលប៉ះពាល់ផ្ទាល់ជាមួយសត្វប្រជៀវនៅប្រទេសអូស្ត្រាលី ឧទាហរណ៍ អ្នកថែប្រជៀវ, ភ្នាក់ងារការពារសត្វព្រៃ និងបសុពេទ្យឬអ្នកដែលធ្វើដំណើរទៅបរទេសដែលមានគំរោងប៉ះថនិកសត្វចេះខាំ និងខ្វាំ ដែលមិនទាន់បានទទួលវ៉ាក់សាំងនោះ គួរឲ្យគ្រូពេទ្យប្រចាំតំបន់របស់ខ្លួនចាក់វ៉ាក់សាំងឲ្យបានគ្រប់ចំនួនក៏រិត។ គេនឹងគិតប្រាក់ចំពោះការចាក់វ៉ាក់សាំងនេះ។

បើទោះជាអ្នកមិនទាន់បានចាក់វ៉ាក់សាំងពីមុនមកក៏ដោយ ក៏ការចាក់វ៉ាក់សាំងឲ្យបានគ្រប់ចំនួនក៏រិត ប្រឆាំង មេរោគជំងឺឆ្កែឆ្កួត ក្រោយពេលមានការប៉ះពាល់ រួមជាមួយការចាក់វ៉ាក់សាំងម្តងទៀតហៅថា rabies immunoglobulin អាចការពារអ្នកពីការឆ្លងរោគបាន ប្រសិនបើគេចាក់ភ្លាមៗបន្ទាប់ពីការខាំឬការខ្វាំរួចនោះ។

- ប្រសិនបើអ្នកត្រូវប្រជៀវ ឬថនិកសត្វព្រៃណាមួយនៅអូស្ត្រាលី (ឬដោយសត្វមិនទាន់ ចាក់វ៉ាក់សាំងដទៃទៀត) ខាំឬខ្វាំ នៅឯបរទេស:

- ចូរលាងសំអាតរបួសនោះជាមួយសាប៊ូនិងទឹកភ្លាមៗឲ្យបានស្អាត
- លាបទឹកថ្នាំសូលុយស្យុងប្រឆាំងមេរោគ
- ទៅឲ្យគ្រូពេទ្យពិនិត្យភ្លាមៗតាមដែលអាចធ្វើបាន ដើម្បីថែរបួសនោះនិងដើម្បីឲ្យដឹងថា តើខ្លួនប្រឈមមុខនិងការឆ្លងរោគឬទេ

ប្រសិនអ្នកប្រឈមមុខនឹងការឆ្លងរោគ អ្នកនឹងចាំបាច់ត្រូវចាក់វ៉ាក់សាំងការពារជំងឺឆ្កែឆ្កួត និង rabies immunoglobulin ឲ្យបានគ្រប់ចំនួនក៏រិត។ នៅក្នុងរដ្ឋ NSW មានការផ្តល់ជូនវ៉ាក់សាំងបង្ការក្រោយពេលមានការប៉ះពាល់ ដោយឥតគិតថ្លៃ សំរាប់វេជ្ជបណ្ឌិតតាមរយៈអង្គភាពសុខភាពសាធារណៈនានា។

ក្រោយពីការខាំឬខ្វាំ ដោយថនិកសត្វមានជម្ងឺរួចមក អ្នកនឹងត្រូវចាក់វ៉ាក់សាំងកាពារម្តងទៀត បើទោះជាពីមុនមកអ្នក ធ្លាប់បានចាក់ម្តងហើយក្តី។ យ៉ាងណាមិញ អ្នកត្រូវការត្រឹមតែវ៉ាក់សាំងបន្ថែមម្តងទៀតប៉ុណ្ណោះ។ ប្រសិនអ្នកបានប្រទះឃើញប្រជៀវដែលមានរបួស ឬ មានជំងឺសូមកុំចាប់ឬកាន់វាឲ្យសោះ ប៉ុន្តែត្រូវទូរស័ព្ទហៅសេវាសង្គ្រោះសត្វព្រៃក្នុងតំបន់របស់អ្នក។

## ព័ត៌មានបន្ថែម – ផ្នែកសុខភាពសាធារណៈ (Public Health) នៅក្នុងរដ្ឋ NSW



**1300 066 055**

**www.health.nsw.gov.au**